Washington State Department of Social & Health Services

ការិយាល័យអភិបាលកិច្ចផ្នែកកុមារ ឬកូនក្មេង

ទាយកដ្ឋានផ្នែកកុមារ និងក្រុមគ្រួសារ

**ការប៉ាន់ប្រមាណអត្រាកំរិតនៃការថែរក្សាកូនចិញ្ចឹម**

FOSTER CARE RATE ASSESSMENT

| កាលបរិច្ឆេទនៃការប៉ាន់ប្រមាណ |
|---|

| | | |
|---|---|---|
| ឈ្មោះកូនក្មេង៖ | អត្តលេខ CAMIS ៖ | កាលបរិច្ឆេទនៃការទុកដាក់កូនក្មេងទៅក្នុងផ្ទះនេះ |
| ឈ្មោះឪពុក/ម្តាយចិញ្ចឹម៖ | | |

| | | | |
|---|---|---|---|
| អាស័យដ្ឋានឪពុក/ម្តាយចិញ្ចឹម៖ | ទីក្រុង៖ | រដ្ឋ៖ | ស៊ីបកូដ៖ |

| | |
|---|---|
| លេខទូរស័ព្ទឪពុក/ម្តាយចិញ្ចឹម(នៅផ្ទះ)៖ | អ្នករៀបចំបំពេញក្រដាសស្នាម៖ |

ការប៉ាន់ប្រមាណនេះ គឺត្រូវបំពេញរួមគ្នាដោយបុគ្គលិកផ្នែកសង្គមកិច្ច និងឪពុក/ម្តាយចិញ្ចឹម ។

ចម្លើយចំពោះសំណួរតទៅនេះ គួរតែមានមូលដ្ឋានទៅលើចំនួនពេលម៉ោងជាមធ្យមក្នុងមួយសប្តាហ៍ សំរាប់អំឡុងពេលប្រាំមួយខែខាងមុខនេះ ដោយប្រើទូវអ្វីដែលគេបានដឹងអំពីសេចក្តីត្រូវការរបស់កូនក្មេង និងសមត្ថភាពរបស់ឪពុក/ម្តាយចិញ្ចឹម ដើម្បីឧបត្ថម្ភដល់សេចក្តីត្រូវការទាំងនោះ ។ សំនួរទាំងអស់នេះ ឆ្លុះបញ្ចាំងនូវសកម្មភាពទាំងនានាដែលសមស្របទៅនឹង ជំនាញការ ហើយនិង ការរំពឹងចំពោះភារៈជាឪពុកម្តាយ ជាប្រក្រតី ។ **ពេលផ្តល់ចម្លើយចំពោះសំណួរទាំងនេះ ឪពុក/ម្តាយចិញ្ចឹមគួរតែគិតដល់កំរិតនៃការថែរក្សា ដែលនឹងផ្តល់ចំពោះកូនក្មេងនេះ ដោយប្រៀបធៀបទៅនឹងកំរិតនៃការថែរក្សា ដែលគេផ្តល់ឲ្យកូនក្មេងកំពុងមាន ការលូតលាស់ជាធម្មតា ហើយនិងមានអាយុដូចគ្នា ។** ឪពុក/ម្តាយចិញ្ចឹមប្រហែលមិនអាចបំពេញនូវសេចក្តីត្រូវការទាំងអស់របស់កូនក្មេង ហើយបើដូច្នេះ ចម្លើយទាំងនាគួរតែឆ្លុះបញ្ចាំងនូវចំនួនពេលវេលា ដែលឪពុក/ម្តាយចិញ្ចឹម រំពឹងថានឹងត្រូវចំណាយទៅលើវិស័យនីមួយៗ ជាមួយនឹងកូនក្មេងម្នាក់ៗ ។

## I. ការថែរក្សាកុមារ

ជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីផ្ចិតអារម្មណ៍ជាពិសេសនឹងការថែរក្សា និង/ឬ ឧបត្ថម្ភគាំទ្រ និងត្រួតពិនិត្យដល់កូនក្មេងសំរាប់កត្តាខាងក្រោមនេះ៖

a. **សេចក្តីត្រូវការខាងផ្លូវកាយ៖**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីផ្តល់នូវកំរិតនៃការថែរក្សា, ឧបត្ថម្ភគាំទ្រ ហើយនិងត្រួតពិនិត្យជាចាំបាច់ ដើម្បីបំពេញសេចក្តីត្រូវការរបស់កូនក្មេង ដោយករណីកូនក្មេងមានជំងឺឃើស្កាត់ ឬលក្ខខ័ណ្ឌផ្លូវកាយ ជាពិសេសណាមួយ?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2-6 ម៉ោងក្នុងមួយសប្តាហ៍ ☐ 6+ ម៉ោងក្នុងមួយសប្តាហ៍

b. **សេចក្តីត្រូវការខាងផ្លូវចរិយា៖**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ក្នុងការផ្តល់នូវកំរិតនៃការថែរក្សា, ឧបត្ថម្ភគាំទ្រ និង ត្រួតពិនិត្យ ដើម្បីបំពេញសេចក្តីត្រូវការរបស់កូនក្មេង ដោយករណីកូនក្មេងមានការរំជួលចិត្ត ឬ លក្ខខ័ណ្ឌផ្លូវចិត្ត, ចរិយា ណាមួយ?

☐ 0-6 ម៉ោងក្នុងមួយសប្តាហ៍ ☐ 6-18 ម៉ោងក្នុងមួយសប្តាហ៍ ☐ 18-44 ម៉ោងក្នុងមួយសប្តាហ៍ ☐ 44+ ម៉ោងក្នុងមួយសប្តាហ៍

## II. ការចូលរួមក្នុងផែនការព្យាបាលរោគរបស់កូនក្មេង

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីចូលរួមក្នុងសកម្មភាពចិញ្ចឹមកូន ដែលទាក់ទងទៅនឹងវិធីថែរក្សាសុខភាពខាងផ្លូវកាយ, ចរិយា, និង ផ្លូវចិត្ត?

a. **ផែនការព្យាបាលរោគខាងផ្លូវកាយ៖**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីផ្តល់នូវសកម្មភាពចិញ្ចឹមកូន ដែលសមស្របជាមួយនឹងគម្រោងការព្យាបាលខាងផ្លូវកាយរបស់កូនក្មេង?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2+ ម៉ោងក្នុងមួយសប្តាហ៍

b. **ផែនការព្យាបាលរោគខាងផ្លូវចិត្ត ឬចរិយា៖**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីផ្តល់នូវសកម្មភាពចិញ្ចឹមកូន ដែលសមស្របជាមួយនឹងគម្រោងការព្យាបាលរោគខាងផ្លូវចិត្ត, ចរិយា របស់កូនក្មេង?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2-6 ម៉ោងក្នុងមួយសប្តាហ៍ ☐ 6-14 ម៉ោងក្នុងមួយសប្តាហ៍ ☐ 14+ ម៉ោងក្នុងមួយសប្តាហ៍

## III. ការអប់រំ និងសិក្សា

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីប្រឡូកចូលរួមក្នុងសកម្មភាពចិញ្ចឹមកូន, ឧបត្ថម្ភគាំទ្រ និងត្រួតពិនិត្យ ដើម្បីបំពេញសេចក្តីត្រូវការខាងការអប់រំរបស់កូនក្មេង?

a. **អន្តរអំពើ ឬអំពើទំនាក់ទំនងរវាងបុគ្គលៈ**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដើម្បីផ្តល់ជំនួយនិងត្រួតពិនិត្យដល់កូនក្មេង ចំពោះកិច្ចការសាលា ដែលត្រូវធ្វើនៅផ្ទះ ហើយនិង/ឬក៏សកម្មភាពរៀនសូត្រផ្សេងៗទៀត?

☐ 0-4 ម៉ោងក្នុងមួយសប្តាហ៍ ☐ 4-8 ម៉ោងក្នុងមួយសប្តាហ៍ ☐ 8-10 ម៉ោងក្នុងមួយសប្តាហ៍ ☐ 10+ ម៉ោងក្នុងមួយសប្តាហ៍

b. **ការគាំទ្រ (ឬផ្តល់ជាបង្អែក) ចំពោះកុមារៈ**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ក្នុងនាមនៃកូនក្មេង, ដើម្បីគាំទ្រកូនក្មេងក្នុងការប្រាស្រ័យទាក់ទងជាមួយគ្រូបង្រៀន, វត្តមាននៅសាលារៀន ក្នុងករណីដែលបានគ្រងទុក ឬមានវិបត្តិភ្លាមៗ, និយាយជាមួយបុគ្គលិកនៃ សាលារៀនតាមទូរស័ព្ទ, ចូលរួមក្នុងកម្មវិធីអភិវឌ្ឍអប់រំបុគ្គលផ្ទាល់ និងត្រួតពិនិត្យសាឡើងវិញ ហៅថា IEP?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2-4 ម៉ោងក្នុងមួយសប្តាហ៍ ☐ 4+ ម៉ោងក្នុងមួយសប្តាហ៍

## IV. ការរៀបចំ, ចាត់កាលវិភាគ, និងត្រួតពិនិត្យសកម្មភាពនានា

a. **ការថែទាំខាងពេទ្យ/ពេទ្យធ្មេញៈ**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដីម្បីចាត់កាលវិភាគសំរាប់ការណាត់ជួប, នាំកំដរកូនក្មេងទៅជួបតាមការណាត់, និងសម្រេចនូវបន្ទុកទទួលខុសត្រូវរបស់ឪពុកម្តាយផ្សេងៗទៀត ដីម្បីរ៉ាប់រងថាកូនក្មេងនឹងបានទទួលនូវការថែទាំជាការចាំបាច់ខាងពេទ្យនិងពេទ្យធ្មេញ?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2-4 ម៉ោងក្នុងមួយសប្តាហ៍ ☐ 4+ ម៉ោងក្នុងមួយសប្តាហ៍

b. **ទស្សនកិច្ច/សកម្មភាពផ្សេងៗរបស់ឪពុកម្តាយៈ**

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដីម្បីចាត់កាលវិភាគ, នាំកំដរ ហើយនិងត្រួតពិនិត្យទស្សនកិច្ចរបស់ឪពុក/ម្តាយ និងបងប្អូនបង្កើតនៃកូនក្មេង, សកម្មភាពនៅសាលារៀន ឬដើរលេងកំសាន្តជាដើម?

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2-6 ម៉ោងក្នុងមួយសប្តាហ៍ ☐ 6-8 ម៉ោងក្នុងមួយសប្តាហ៍ ☐ 8+ ម៉ោងក្នុងមួយសប្តាហ៍

## V. ការថែទាំរក្សាផ្ទះសម្បែង

ចំនួនជាមធ្យមក្នុងមួយសប្តាហ៍ តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដីម្បីជួសជុល, ផ្លាស់ប្តូរ, ឬបោសសំអាតផ្ទះ ឬប្រដាប់ប្រដានៅក្នុងផ្ទះ ដែលលើសពីកំរិតធម្មតា ដោយសារតែលក្ខខ័ណ្ឌ ឬចរិយារបស់កូនក្មេងនេះ ដែលបណ្តាលមកពីកត្តាខាងក្រោម?

a. **លក្ខខ័ណ្ឌជាប្រចាំ ឬរ៉ាំរ៉ៃៈ**

ចូររាប់ទាំងពេលវេលាដែលត្រូវចំណាយលើការជួសជុល, ផ្លាស់ប្តូរ, និងបោសសំអាត ដោយសារតែលក្ខខ័ណ្ឌជាប្រចាំមិនដាច់(ក្រៅពីកត្តាអាយុ) ដែលកូនក្មេងមានការត្រួតត្រាដ៏តិចតួច ឬក៏អត់សោះ ដូចជាការនោមដាក់គ្រែ ឬការមិនអាចវៀរចាកមេថុនបាន, កង្វះខាតនូវការត្រួតត្រាលើសាច់ដុំ, និងភាពមិនដឹងនូវផលវិបាកនៃអំពើផ្លូវកាយរបស់ខ្លួន ។

☐ 0-1 ដងក្នុងមួយសប្តាហ៍ ☐ 1-3 ដងក្នុងមួយសប្តាហ៍ ☐ 3-7 ដងក្នុងមួយសប្តាហ៍ ☐ 7+ ដងក្នុងមួយសប្តាហ៍

b. **ចរិយាបំផ្លេចបំផ្លាញៈ**

ចូររាប់ទាំងពេលវេលាដែលត្រូវចំណាយលើការជួសជុល, ផ្លាស់ប្តូរ, និងបោសសំអាត ដោយសារតែចរិយាបំផ្លេចបំផ្លាញដោយចេតនារបស់កូនក្មេង ដែលបណ្តាលមកពីការប៉ះទង្គិច ឬការរំខានខាងផ្លូវចិត្ត ឬខួរក្បាល ។

☐ 0-1 ដងក្នុងមួយសប្តាហ៍ ☐ 1-3 ដងក្នុងមួយសប្តាហ៍ ☐ 3+ ដងក្នុងមួយសប្តាហ៍

## VI. ការប្រុងប្រៀបរៀបចំកុមារសំរាប់ការផ្លាស់ប្តូរ

ចំនួនជាមធ្យម តើឪពុក/ម្តាយចិញ្ចឹម នឹងត្រូវចំណាយពេលប៉ុន្មានម៉ោង ដីម្បីប្រុងប្រៀបរៀបចំកុមារសំរាប់ការផ្លាស់ប្តូរទៅឲ្យក្រុមគ្រួសារដើមកំណើតវិញ ឬឲ្យគ្រួសាររើសយកមកចិញ្ចឹម ឬទុកដាក់នៅកន្លែងផ្សេង? ចូររាប់ទាំងពេលវេលាដែលត្រូវចំណាយ ក្នុងការបង្ហាញនូវវិធីចិញ្ចឹមកូនល្អ។ ដល់ក្រុមគ្រួសារដើមកំណើត ហើយនិងញាតិសន្តាន, ការរៀបចំសៀវភៅជីវិតសំរាប់កូនក្មេង, ហើយនិងសកម្មភាពនានា ដែលរៀបចំឡើងដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរដ៏ងាយស្រួលមួយ, ឬក៏ដើម្បីជួយក្នុងការបែកចេញទៅរស់នៅដោយខ្លួនឯងរបស់កូនក្មេងនោះ ។

☐ 0-2 ម៉ោងក្នុងមួយសប្តាហ៍ ☐ 2+ ម៉ោងក្នុងមួយសប្តាហ៍